ឆ្នាំ ទី ៧ លេខ ៣៣ សប្តាហ៍ ទី ១ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៧ រាជកិច្ច ទំព័រ ៣៨៣៩

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៩ សហវ.

លិខិតចូល ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ 2007

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០៧*

## សេចក្តីជូនដំណឹង

### ស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ ប្រកបសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងជាថ្មីម្តងទៀតដល់ លោក លោកស្រី ដែលកំពុងប្រកបសេវាកម្មវាយតំលៃ ឬសេវាកម្មទិញ លក់ ជួល អចលនវត្ថុ នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ អោយបានជ្រាបថា កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការចុះផ្សាយតាមរយៈសារពត៌មានក្នុងស្រុកដោយអញ្ជើញ លោក លោកស្រី ដែលបាននិងកំពុងប្រកបសេវាកម្មជាក្រុមហ៊ុនវាយតំលៃអចលនវត្ថុ និង ក្រុមហ៊ុនអចលនវត្ថុ (ទិញ លក់ ជួល អចលនវត្ថុ)ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មកដាក់ពាក្យសុំវិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ ដើម្បីប្រកបសេវាកម្មជាក្រុមហ៊ុនវាយតំលៃ ឬជាក្រុមហ៊ុនអចលនវត្ថុ ។ រហូតមកដល់ពេលនេះ យើងពិនិត្យឃើញថា មានក្រុមហ៊ុនជាច្រើនបានរួសរាន់មកដាក់ពាក្យរួចរាល់ហើយ ប៉ុន្តែក៏នៅមានក្រុមហ៊ុនមួយចំនួនតូច ដែលមិនទាន់បានមកដាក់ពាក្យ ។ ដូច្នេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមអញ្ជើញ លោក លោកស្រី ដែលកំពុងប្រកបសេវាកម្មខាងលើ ហើយមិនទាន់បានមកដាក់ពាក្យ មេត្តារួសរាន់មកដាក់ពាក្យអោយបានមុនដំណាច់ **ខែ ឧសភា ឆ្នាំ ២០០៧** នៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ) នៅរៀងរាល់ម៉ោងធ្វើការ ។ ពត៌មានបន្ថែមសូមទំនាក់ទំនងមកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**<u>សំគាល់:</u>** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងអនុវត្តទៅតាមផ្លូវច្បាប់ចំពោះអ្នកប្រកបសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុទាំងឡាយណាដែលពុំព្រមអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ លេខ ១៤២ សហវ. ប្រក. ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**<u>ទូរស័ព្ទទំនាក់ទំនង:</u>**

- ០២៣ ៤២៧ ៩៣៥
- ០១២ ៨៣០ ០០៩
- ០១២ ២០០ ០៦១
- ០១១ ៨៦៨ ៩៦១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់